ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញៈ ថ្ងៃទី ២៥ ខែមីនា ២០១៤ ដោយ អគ្គនាយកដ្ឋានពន្ធដារ

ដើម្បីពង្រឹង និងធ្វើឲ្យកាន់តែប្រសើរឡើងនូវសេវាសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងការផ្តល់ជូនអ្នកជាប់ពន្ធ និងងាយស្រួលក្នុងការគ្រប់គ្រងអ្នកជាប់ពន្ធ ក៏ដូចជាអគ្គនាយកដ្ឋានពន្ធដារនឹងដាក់ឲ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា (IT) និងប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Data Center) តាមប្រព័ន្ធអេឡិចត្រូនិកក្នុងទិសដៅនៃការកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលកម្ពុជា អគ្គនាយកដ្ឋានពន្ធដារគ្រោងនឹងរៀបចំដាក់ឲ្យប្រើប្រាស់នូវប្រព័ន្ធព័ត៌មានវិទ្យា តាមរយៈ ៖

- ការដាក់លិខិតប្រកាសតាមប្រព័ន្ធអ៊ីនធើណែត (E-Filling) សម្រាប់អ្នកជាប់ពន្ធ ។
- ការគ្រប់គ្រងទិន្នន័យនៃការបង់ប្រាក់ពន្ធរបស់អ្នកជាប់ពន្ធជាមួយធនាគារ ។
- ការបង់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក (E-Payment) គឺមានន័យថា អ្នកជាប់ពន្ធអាចបង់ពន្ធនៅទីណាក៏បាន ដោយពុំបាច់មកកាន់អគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារទេ ។
- ការធ្វើការភ្ជាប់ប្រព័ន្ធទិន្នន័យរបស់អ្នកជាប់ពន្ធនៅតាមសាខាពន្ធដារទូទាំងប្រទេស មកកាន់អគ្គនាយកដ្ឋានពន្ធដារ (Centralized Data) ។
- ការភ្ជាប់ប្រព័ន្ធផ្ទៀងផ្ទាត់នៃការបង់ពន្ធរបស់ធានាគារឯកជន ជាមួយប្រព័ន្ធបង់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ ។

ស្ថិតក្នុងបរិបទនេះហើយ ទើបកាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៤ កន្លងទៅ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានដឹកនាំគណប្រតិភូជាន់ខ្ពស់របស់អគ្គនាយកដ្ឋានពន្ធដារ ទៅបំពេញទស្សនៈកិច្ចនៅអាជ្ញាធរចំណូលផ្ទៃក្នុងរបស់ប្រទេសម៉ាឡេស៊ុ ដើម្បីធ្វើការសិក្សាស្វែងយល់ និងចែករំលែកបទពិសោធន៍ទាក់ទងនឹងប្រព័ន្ធព័ត៌មានវិទ្យារបស់អាជ្ញាធរចំណូលផ្ទៃក្នុងរបស់ប្រទេសម៉ាឡេស៊ី ដោយផ្តោតជាសំខាន់លើ ៖

- ការស្វែងយល់អំពីដំណើការនៃការប្រមូលពន្ធរបស់អាជ្ញាធរចំណូលផ្ទៃក្នុងនៃប្រទេសម៉ាឡេស៊ុ និងការពិនិត្យមើលលើសន្តិសុខ បច្ចេកទេសនៃការគ្រប់គ្រង និងការតាមដានពីបញ្ហានានាដែលពាក់ព័ន្ធទៅនឹងសន្តិសុខផ្នែកព័ត៌មានវិទ្យា ។
- ការប្រើប្រាស់សេវាតាមប្រព័ន្ធអេឡិចត្រូនិច (E-Services) ដើម្បីបង្កលក្ខណៈងាយស្រួលចំពោះអ្នកជាប់ពន្ធ និងសម្រាប់អគ្គនាយកដ្ឋានពន្ធដារក្នុងការតាមដានពិនិត្យមើលទិន្នន័យនានាបានយ៉ាងឆាប់រហ័ស ជាពិសេសតាមដានការប្រកាសបង់ពន្ធ របស់អ្នកជាប់ពន្ធ ។
- ការស្វែងយល់អំពីរបៀបគ្រប់គ្រងទិន្នន័យរបស់អ្នកជាប់ពន្ធនៅក្នុងមជ្ឈមណ្ឌលឯកសារ (Document Center) ជាពិសេស ការបង្កើត Application សម្រាប់បញ្ចូលទិន្នន័យ ការជ្រើសរើស និងការវាយតម្លៃក្រុមហ៊ុន ឬអ្នកជាប់ពន្ធដែលមានហានិភ័យខ្ពស់ សម្រាប់មកធ្វើសវនកម្ម ។

ជាងនេះទៅទៀត គណៈប្រតិភូបានផ្លាស់ប្តូរបទពិសោធន៍ការងារស្តីពីដំណើការនៃការគ្រប់គ្រង និងចាត់ចែងលិខិតប្រកាស ការរក្សាទុកនូវឯកសាររបស់អ្នកជាប់ពន្ធប្រកបដោយសុវត្ថិភាព និងមានប្រសិទ្ធិភាពខ្ពស់ ផងដែរ ។

ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងជាប្រធានគណៈប្រតិភូ បានសម្តែងនូវសេចក្តីសប្បាយរីករាយ និងថ្លែងអំណរគុណចំពោះអាជ្ញាធរចំណូលពន្ធដាររបស់ប្រទេសម៉ាឡេស៊ី ដែលបានទទួលស្វាគមន៍គណៈប្រតិភូជាន់ខ្ពស់នៃអគ្គនាយកដ្ឋានពន្ធដារ និងចូលរួមចែករំលែកបទពិសោធន៍ល្អៗជាច្រើន ដល់គណៈប្រតិភូកម្ពុជា ។




អគ្គនាយកដ្ឋានពន្ធដារ